**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**
**អគ្គលេខាធិការដ្ឋាន**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៦

អគ្គលេខាធិការដ្ឋានរដ្ឋសភាសូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា នៅព្រឹកថ្ងៃព្រហស្បតិ៍ ១១រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ព្រឹទ្ធសមាជិករដ្ឋសភា និងជាប្រធានរដ្ឋសភាបណ្តោះអាសន្ន ដោយមានវត្តមានបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រនីតិកាលទី៦ ចំនួន ១២៥រូប។

របៀបវារៈសម័យប្រជុំរដ្ឋសភា គឺការបោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញ នៃរដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល ។

ជាកិច្ចចាប់ផ្តើមសម័យប្រជុំ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** បានជម្រាបជូនអង្គសភាថា រដ្ឋសភាបានទទួលលិខិតដែលមានដូចខាងក្រោម៖

- លិខិតរបស់គណបក្សប្រជាជនកម្ពុជា លេខ ០៣៧/១៨ លគ.គក ចុះថ្ងៃពុធ ១០រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ស្តីពីបញ្ជីរាយនាមសមាសភាពប្រធាន អនុប្រធានរដ្ឋសភា និងប្រធាន អនុប្រធានគណៈកម្មការជំនាញ នៃរដ្ឋសភា នីតិកាលទី៦
- លិខិតស្នើរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃពុធ ១០រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២។

**ចំពោះលទ្ធផលសម័យប្រជុំរដ្ឋសភា មានដូចខាងក្រោម៖**

**១**- អង្គសភា បានអនុម័តរបៀបវារៈ មានចំនួន ១២៥សំឡេង។



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៥ សារអេឡិចត្រូនិច: sg@national-assembly.org.kh គេហទំព័រ: www.national-assembly.org.kh

២- អង្គសភា បានបោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំង ប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាលនៅដើមនីតិកាលទី៦ ដោយវិធីលើកដៃនិងដោយសំឡេង ១២៥លើ១២៥ នៃសមាជិករដ្ឋសភាទាំងមូល។

**២-១. សមាសភាពប្រធាន អនុប្រធានរដ្ឋសភា និងប្រធាន អនុប្រធានគណៈកម្មការជំនាញនានារដ្ឋសភា មានដូចតទៅ៖**

១. ប្រធានរដ្ឋសភា ៖ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

២. អនុប្រធានទី ១រដ្ឋសភា៖ **ឯកឧត្តមបណ្ឌិត ខួន សុដារី**

៣. អនុប្រធានទី ២រដ្ឋសភា៖ **លោកជំទាវ ឃួន សុដារី**

**គណៈកម្មការជំនាញ**

១. គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា

-ប្រធាន៖ ឯកឧត្តម **ប៉ា សុជាតិវង្ស**

-អនុប្រធាន៖ លោកជំទាវ **ចាន ស្រីមុំ**

២. គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

-ប្រធាន៖ ឯកឧត្តមបណ្ឌិត **ជាម យៀប**

-អនុប្រធាន៖ ឯកឧត្តម **ឡូយ សុផាត**

៣. គណៈកម្មការផែនការវិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

-ប្រធាន៖ ឯកឧត្តម **ជា វ៉ាន់ដេត**

-អនុប្រធាន៖ ឯកឧត្តម **ហ៊ី ស្រ៊ី**

៤. គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ

-ប្រធាន៖ ឯកឧត្តម **ហ៊ីន ឈោង**

-អនុប្រធាន៖ ឯកឧត្តម **ប្រាជ្ញ ចន្ទ**

៥. គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

-ប្រធាន៖ ឯកឧត្តម **ឈាង វុន**

-អនុប្រធាន៖ ឯកឧត្តម **សួស យ៉ារ៉ា**

៦. គណៈកម្មការនីតិកម្ម និងយុត្តិធម៌

-ប្រធាន៖ ឯកឧត្តមបណ្ឌិត **ម៉ែន បញ្ញា**

-អនុប្រធាន៖ លោកជំទាវ **គ្រួច សំអាន**

៧. គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍

-ប្រធាន៖ ឯកឧត្តម **ហ៊ុន ម៉ានី**

-អនុប្រធាន៖ លោកជំទាវ **ឯម ប៉ុណ្ណា**

៨. គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

-ប្រធាន៖ លោកជំទាវ **ឡោក ខេង**

-អនុប្រធាន៖ ឯកឧត្តម **ប៉ាល់ សំអឿន**

៩. គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ប្រធាន៖ លោកជំទាវ **និន សាផុន**

-អនុប្រធាន៖ ឯកឧត្តម **សុខ សុភាន**

១០. គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ

-ប្រធាន៖ ឯកឧត្តម **ម៉ែន ស៊ីមន**

-អនុប្រធាន៖ លោកជំទាវ **ត្រឹង ថាវី**

**២-២. សមាសភាពរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាសម្រាប់នីតិកាលទី ៦ នៃរដ្ឋសភា មានដូចតទៅ៖**

I. **នាយករដ្ឋមន្ត្រី**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

II. **ឧបនាយករដ្ឋមន្ត្រី**

១. សម្តេចក្រឡាហោម **ស ខេង**

២. សម្តេចពិជ័យសេនា **ទៀ បាញ់**

៣. ឯកឧត្តម **ហោ ណាំហុង**

៤. លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន**

៥. ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** (ប្រចាំការ)

៦. ឯកឧត្តម **យឹម ឆៃលី**

៧. ឯកឧត្តម **កែ គឹមយ៉ាន**

៨. ឯកឧត្តម **ប្រាក់ សុខុន**

៩. ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

១០. ឯកឧត្តម **ជា សុផារ៉ា**

III. **ទេសរដ្ឋមន្ត្រី**

១. ឯកឧត្តម **ឆាយ ថន**

២. ឯកឧត្តម **ប៉ុល សារឿន** (ទទួលបន្ទុកបេសកកម្មពិសេស)

៣. ឯកឧត្តម **គន់ គីម** (ទទួលបន្ទុកបេសកកម្មពិសេស)

៤. ឯកឧត្តម **មាស សុផា** (ទទួលបន្ទុកបេសកកម្មពិសេស)

៥. ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ**

៦. ឯកឧត្តម **ញឹម វណ្ណដា** (ទទួលបន្ទុកបេសកកម្មពិសេស)

៧. ឯកឧត្តម **ស៊ុន ចាន់ថុល**

៨. ឯកឧត្តម **ឱម យ៉ិនទៀង** (ទទួលបន្ទុកបេសកកម្មពិសេស)

៩. ឯកឧត្តម **អៀង ម៉ូលី** (ទទួលបន្ទុកបេសកកម្មពិសេស)

១០. ឯកឧត្តម **អ៊ា គឹមហុង** (ទទួលបន្ទុកបេសកកម្មពិសេស)

១១. ឯកឧត្តម **យឹម ណុលឡា** (ទទួលបន្ទុកបេសកកម្មពិសេស)

១២. ឯកឧត្តម **ហ៊ឹម ឆែម**

១៣. ឯកឧត្តម **ជិន ប៊ុនសឿន** (ទទួលបន្ទុកបេសកកម្មពិសេស)

១៤. ឯកឧត្តម **ហូ សិទ្ធី** (ទទួលបន្ទុកបេសកកម្មពិសេស)

១៥. ឯកឧត្តម **ឃុន ហាំង** (ទទួលបន្ទុកបេសកកម្មពិសេស)

១៦. ឯកឧត្តម **លី ធុជ** (ទទួលបន្ទុកបេសកកម្មពិសេស)

១៧. ឯកឧត្តម **អូស្មាន ហាសាន់** (ទទួលបន្ទុកបេសកកម្មពិសេស)

IV. **រដ្ឋមន្ត្រី**

១. ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

២. សម្តេចក្រឡាហោម **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

៣. សម្តេចពិជ័យសេនា **ទៀ បាញ់** រដ្ឋមន្ត្រីក្រសួងការពារជាតិ

៤. ឯកឧត្តម **ប្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

៥. ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៦. ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៧. ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

៨. ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

៩. ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

១០. ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

១១. ឯកឧត្តម **ឆាយ ថន** រដ្ឋមន្ត្រីក្រសួងផែនការ

១២. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

១៣. ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

១៤. ឯកឧត្តម **ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

១៥. ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន

១៦. ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

១៧. ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន

១៨. ឯកឧត្តម **អង្គ វង្សវឌ្ឍានា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

១៩. លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

២០. ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២១. ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល

២២. ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

២៣. លោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

២៤. ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍

២៥. ឯកឧត្តម **ហ៊ឹម ឆែម** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

២៦. លោកជំទាវ **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

២៧. ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

២៨. ឯកឧត្តម **ពេជ្រ ប៊ុនធិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

២៩. ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

បន្ទាប់មក **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា បានអញ្ជើញ **ឯកឧត្តមបណ្ឌិត ខួន ញឹល** អនុប្រធានទី១ រដ្ឋសភា និង**លោកជំទាវ ឃួន សុដារី** អនុប្រធានទី២

រដ្ឋសភា និងសមាសភាពសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា មកកាន់អាសនៈ។

នៅក្នុងឱកាសនោះ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** បានមានប្រសាសន៍ថ្លែងនូវអំណរព្រះគុណមហាករុណាទិគុណជាអនេកកប្បការថ្វាយ **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ដែលទ្រង់បានសព្វព្រះរាជហឫទ័យ យាងជាព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត នៅក្នុងការបើកសម័យប្រជុំដំបូង នីតិកាលទី៦ នៃរដ្ឋសភា។ តំណាង សមាជិក សមាជិការដ្ឋសភា **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** សូមគោរពថ្វាយ ព្រះរាជសព្ទសាធុការពរ សូមព្រះអង្គមានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រមទាំងព្រះរាជជន្មាយុយឺនយូរ ដើម្បីគង់ជាម្លប់ដ៏ត្រជាក់ត្រជុំ ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ សម្រាប់កូនចៅជនរួមជាតិទូទៅ ស្ថិតក្នុងសុខសន្តិភាព និងស្ថិរភាពរឹងមាំយូរអង្វែង។

ក្នុងនាមរដ្ឋសភា **សម្តេច** សូមសម្តែងការកោតសរសើរ និងសូមថ្លែងអំណរគុណដោយក្តីដឹងគុណជានិច្ច ចំពោះជនរួមជាតិគ្រប់លំដាប់ថ្នាក់នៅទូទាំងប្រទេស ដែលបានបំពេញកាតព្វកិច្ចដ៏ឧត្តុង្គឧត្តមថ្លៃថ្លាបំផុត ក្នុងនាមប្រជាពលរដ្ឋចូលរួមចំណែកសម្តែងឆន្ទៈគាំទ្រចំពោះ សម្តេច ឯកឧត្តម លោកជំទាវ នៅក្នុងគណបក្សនយោបាយនានាដែលជនរួមជាតិពេញចិត្តតាមរយៈការបោះឆ្នោតជាលក្ខណៈសកលសម្រាប់នីតិកាលទី៦នេះ ក្នុងបរិយាកាសថ្លៃថ្នូរ តម្លាភាព ត្រឹមត្រូវ សេរី និងយុត្តិធម៌ ផ្អែកតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។ សម្តេចបានថ្លែងអំណរគុណចំពោះអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងបណ្តាប្រទេសជាមិត្ត ដែលគាំទ្រលើការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភានីតិកាលទី៦នេះ។

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** បានប្រកាសជាឱឡារិកថា ដោយឈរលើមូលដ្ឋានរដ្ឋធម្មនុញ្ញរបស់ជាតិ និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រមទាំងគោលការណ៍ច្បាប់នានាជាមូលដ្ឋាន សម្តេចនឹងខិតខំគ្រប់សកម្មភាពបំពេញភារកិច្ចលើកកម្ពស់តួនាទី ពិតប្រាកដរបស់រដ្ឋសភា ក្នុងកិច្ចការកសាងច្បាប់ ការងារត្រួតពិនិត្យ ការអនុវត្តន៍ច្បាប់ និងការពារផលប្រយោជន៍ជនរួមជាតិទូទៅជាម្ចាស់ឆ្នោត។

បន្ទាប់មក **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** បានអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាមានមតិជូនអង្គសភា។

សម័យប្រជុំរដ្ឋសភាលើកទី១នីតិកាលទី៦ បានប្រកាសផ្អាកសម័យប្រជុំនៅវេលាម៉ោង ៩:០៩នាទី ថ្ងៃខែឆ្នាំដដែល។ សម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៦ បន្តទៀត នឹងមានជូនដំណឹងនៅពេលក្រោយ។

អាស្រ័យដូចជម្រាបជូនខាងលើនេះ សូមសាធារណជន មេត្តាជ្រាប។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ២០១៨

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**